# មេរៀនទី ១៣៨៖ ជាតិសាសន៍អ៊ីស្រាអែលត្រូវបាន បែងចែកជាពីរ

## ១ ពង្សាវតារក្សត្រ ១១៖២៨-១២៖២៤

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/SI77KiqRfs0

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/Fpr702shz_A

**គោលបំណង៖ ព្រះទុកជម្រើសឲ្យយើង។**

**ខគម្ពីរចងចាំ៖ យ៉ូប ៣៤៖៤** *"សូមឲ្យយើងរាល់គ្នារើសយកសេចក្ដីណាដែលត្រឹមត្រូវ សំរាប់ពួកយើង ហើយឲ្យយើងបានស្គាល់សេចក្ដីដែលល្អនៅក្នុងចំណោមយើង។"*

**ចំរៀង** ( *យូធូបលីង* )៖

១.គឺជាការល្អ https://youtu.be/Z91SULEHfho

២.ខ្ញុំដើរតាមព្រះយេស៊ូវ https://youtu.be/aasilZXGorc

៣.ខ្ញុំបានសម្រេចចិត្ត https://youtu.be/MR1Yv--Q4oo

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត «បែងចែកទុយោ»

សម្ភារៈដែលត្រូវការ៖ កាត់ទុយោបឺតមួយចំនួនដូចរូបដែលមានពណ៌ចម្រុះ កែវ២ កៅអី១ ចាន១



១. ចែកកុមារជា ២ ក្រុមស្មើគ្នា ដោយក្រុមមួយជាក្រុមក្រហម និងក្រុមមួយទៀតជាក្រុមខៀវ ដាក់លេខរៀងសម្រាប់សិស្សគ្រប់ៗគ្នា

២. ដាក់កៅអីនៅចុងម្ខាងនៃថ្នាក់រៀន ដោយដាក់ចានដែលមានទុយោបឺត កាត់រួចពណ៌ចម្រុះនៅក្នុង នោះពីលើកៅអី

៣. នៅពេលដែលគ្រូហៅលេខរបស់គេ ក្រុមនីមួយៗត្រូវឲ្យសមាជិកក្រុមនោះរត់ទៅរើសទុយោបឺត ដែលតំណាងឲ្យពណ៌ក្រុមរបស់ខ្លួននោះ ដាក់ទៅក្នុងកែវក្រុជាសមួយនៅជិតនោះ កុមារម្នាក់មានពេលតែ ១០ វិនាទីប៉ុណ្ណោះក្នុងការលេង។

៤. នៅពេលគូរទី១លេងចប់គូរបន្ទាប់ត្រូវត្រៀមខ្លួនក្នុងការលេងបន្ត បន្តលេងល្បែងនេះរហូតដល់កុមារគ្រប់គ្នាបានលេងអស់។

៥. ក្រុមណាដែលអាចយកទុយោពណ៌ក្រុមរបស់ខ្លួន ដាក់ក្នុងកែវក្រុមខ្លួនបានច្រើនជាងគេក្រុមនោះជាអ្នកឈ្នះ។ បើក្រុមណារើសមកខុសពណ៌ក្រុមនោះនឹងចាញ់ល្បែងនេះ។

៦. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ការដែលជ្រើសខុសនោះនឹងធ្វើឲ្យក្រុមរបស់យើងចាញ់គេ ដូច្នេះយើងត្រូវតែប្រុងប្រយ័ត្នក្នុងការធ្វើការចម្រេចចិត្តមិនថានៅក្នុងជីវិតរស់នៅក៏ដោយ។

### ៤. ការណែនាំមេរៀន

សូមក្រឡេកទៅមើលខោអាវដែលយើងពាក់ឥឡូវនេះ។ តើនរណាជាអ្នកជ្រើសខោអាវនេះ? តើនរណាជាអ្នកសម្រេចចិត្តមកព្រះវិហារនៅថ្ងៃនេះ? តើអ្នកណាជាអ្នកបង្កើតជម្រើសនេះ? ព្រះបានផ្ដល់ឲ្យយើងនូវជម្រើសជាច្រើននៅក្នុងជីវិតរស់នៅ។ ជម្រើសខ្លះគឺពិតជាងាយស្រួលក្នុងការធ្វើ។ តែជម្រើសខ្លះមិនងាយ

ស្រួលនោះទេ។ ពេលខ្លះយើងធ្វើការជ្រើសរើសបានល្អត្រឹមត្រូវ តែពេលខ្លះទៀតមិនបានល្អនោះទេ។ ប៉ុន្តែព្រះនៅតែអនុញ្ញាតឱ្យយើងជ្រើសរើស។ ព្រះសន្យាថានឹងនៅជាមួយយើងជារៀងរាល់ថ្ងៃដើម្បីជួយយើង។ នៅពេលដែលយើងធ្វើការជ្រើសរើសល្អ នោះរឿងល្អៗនឹងកើតឡើងចំពោះយើង។ ហើយពេលយើងសម្រេចចិត្តមិនបានល្អ នោះរឿងអាក្រក់នឹងកើតឡើងចំពោះយើង។ ថ្ងៃនេះយើងនឹងរៀនអំពីបុរសម្នាក់ដែលបានធ្វើការជ្រើសរើសមិនបានត្រឹមត្រូវមួយចំនួន។ តើអ្នកគិតថានឹងមានអ្វីកើតឡើងចំពោះគាត់?

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ស្តេចសាឡូម៉ូនជាបុរសដែលមានប្រាជ្ញាបំផុតក្នុងលោក។ គាត់បានសុំប្រាជ្ញាពីព្រះ ព្រោះគាត់ចង់ក្លាយជាស្តេចដ៏ល្អ។ នេះជាជម្រើសដ៏ល្អដែលគាត់បានធ្វើ ហើយព្រះជាម្ចាស់ពិតជាសព្វព្រះទ័យណាស់។ ព្រះបានសន្យានឹងស្តេចសាឡូម៉ូនថា ទ្រង់នឹងគ្រប់គ្រងលើជនជាតិអ៊ីស្រាអែលទាំងមូល ប្រសិនបើទ្រង់ស្តាប់បង្គាប់ព្រះ។ អ៊ីស្រាអែលមានកុលសម្ព័ន្ធចំនួន ១២ ហើយស្តេចសាឡូម៉ូនជាស្តេចដែលគ្រប់គ្រងលើកុលសម្ព័ន្ធទាំង១២នោះ។ សាឡូម៉ូនបានស្តាប់បង្គាប់ព្រះមួយរយៈ ហើយគាត់គ្រប់គ្រងប្រទេសរបស់គាត់ដោយប្រាជ្ញា។ ប៉ុន្តែ ស្តេចសាឡូម៉ូនបានសម្រេចចិត្តខុសនូវរឿងមួយចំនួន។ គាត់បានជ្រើសរើសថ្វាយបង្គំព្រះដទៃ!

មានបុរសម្នាក់ឈ្មោះយេរ៉ូបោម ជាមន្ត្រីដែលស្តេចសាឡូម៉ូនទុកចិត្តបំផុត។ ថ្ងៃមួយ ហោរាម្នាក់បានមក។ ហោរាគឺជាអ្នកដែលស្តាប់ព្រះ ហើយប្រាប់មនុស្សពីអ្វីដែលព្រះមានបន្ទូល។ ហោរានោះបានប្រាប់យេរ៉ូបោមថា ព្រះនឹងយកកុលសម្ព័ន្ធ១០ ក្នុងចំណោមកុលសម្ព័ន្ធទាំង១២ របស់ស្តេចសាឡូម៉ូន ហើយប្រគល់ពួកគេទៅឲ្យយេរ៉ូបោម។ យេរ៉ូបោមនឹងក្លាយជាស្តេចថ្មី។ ព្រះបានសម្រេចចិត្តធ្វើដូច្នេះ ដោយសារសាឡូម៉ូន បានជ្រើសរើសបែរខ្នងដាក់ព្រះ។

ហោរាប្រាប់យេរ៉ូបោមថា ព្រះនឹងគង់នៅជាមួយនឹងគាត់ បើគាត់ស្តាប់បង្គាប់ព្រះ ហើយធ្វើតែអ្វីដែលត្រឹមត្រូវ។ អ្វីគ្រប់យ៉ាងបានកើតឡើងដូចដែលព្រះបានមានបន្ទូលមែន។ យេរ៉ូបោមបានឡើងសោយរាជ្យលើកុលសម្ព័ន្ធ១០ ក្នុងចំណោមកុលសម្ព័ន្ធទាំង១២របស់ស្តេចសាឡូម៉ូន។ ដែលរាជាណាចក្រមួយហៅថា **អ៊ីស្រាអ៊ែល**។ ហើយមួយទៀតដែលគ្រប់គ្រងដោយកូនចៅស្តេចសាឡូម៉ូន ត្រូវបានគេហៅថា **យូដា**។ ដូច្នេះជាតិសាសន៍អ៊ីស្រាអ៊ែលត្រូវបានបែងចែកជាពីរ។ ដំបូងឡើយ យេរ៉ូបោមបាន ជ្រើសរើសធ្វើល្អដើម្បីដើរតាមព្រះ ប៉ុន្តែក្រោយមកគាត់បានសម្រេចចិត្តខុសដូចសាឡូម៉ូនដែរ។ យេរ៉ូបោម បានធ្វើគោមាសពីរសម្រាប់ប្រជារាស្ត្រថ្វាយបង្គំ! ព្រះមិនសព្វព្រះទ័យចំពោះជម្រើសដ៏អាក្រក់នេះទេ។

យើងតែងតែធ្វើការជ្រើសរើសជារៀងរាល់ថ្ងៃ។ ការជ្រើសរើសរបស់យើងអាចធ្វើឱ្យជីវិតរបស់យើងដើរក្នុងទិសដៅផ្សេងៗគ្នាជាច្រើន។ ការជ្រើសរើសរបស់យើងខ្លះធ្វើឲ្យព្រះសព្វព្រះទ័យ។ តែការជ្រើសរើសខ្លះទៀតធ្វើឲ្យព្រះមិនសព្វព្រះទ័យទេ។ ព្រះសព្វព្រះទ័យឲ្យយើងមានសេរីភាពក្នុងការជ្រើសរើស ដូច្នេះពេលយើងជ្រើសរើសស្តាប់បង្គាប់ទ្រង់ ដោយធ្វើតែអ្វីដែលត្រឹមត្រូវ នោះមានន័យថាយើងធ្វើដោយសារយើងស្រឡាញ់ទ្រង់ ហើយចង់បម្រើព្រះអង្គ។ សូមអរគុណព្រះដែលបានផ្តល់ជម្រើសដល់យើង!

## ៦. សំនួរពិភាក្សា

១. តើព្រះបានសន្យាចំពោះសាឡូម៉ូនដូចម្តេចខ្លះប្រសិនបើសាឡូម៉ូនស្តាប់បង្គាប់ទ្រង់?
*(គាត់នឹងគ្រប់គ្រងលើជនជាតិអ៊ីស្រាអែលទាំងមូល)*

២. តើព្រះបានយកកុលសម្ព័ន្ធ១០ ក្នុងចំណោមកុលសម្ព័ន្ធទាំង១២ របស់ស្តេចសាឡូម៉ូនឲ្យទៅនរណាជាអ្នកគ្រប់គ្រង? *(យេរ៉ូបោម)*

៣. តើយេរ៉ូបោមបានធ្វើអ្វីឲ្យប្រជារាស្ត្ររបស់គាត់គោរព? *(គោមាសពីរ)*

៤. តើយើងគួរជ្រើសរើសដូចម្ដេចដើម្បីឲ្យព្រះសព្វព្រះទ័យ? *(ស្ដាប់បង្គាប់ព្រះ)*

## ៧. ល្បែងកំសាន្ត «ការជ្រើសរើស»

សម្ភារៈដែលត្រូវការ៖ រូបឆ្មា រូបឆ្កែ កាដូ៣ ដែលមួយដាក់ដុំថ្ម មួយដាក់ស្ករគ្រាប់ និងមួយទៀតអត់ដាក់អ្វីទាំងអស់



១. ចែកកុមារជាពីរក្រុម ហើយឲ្យពួកគេឈរជាជួរ

២. ឲ្យក្រុមទាំងពីរជ្រើសរើសរូបមួយ ឆ្មា ឬក៏ឆ្កែ ហើយធ្វើសម្លេងគ្រាប់តាមសត្វនោះ



៣. នៅពេលដែលគ្រូហៅក្រុមណាមួយ (ឆ្មា ឬក៏ឆ្កែ) ក្រុមទាំងពីរត្រូវស្រែកឲ្យលឺតាមដែលអាចធ្វើទៅបាន។ ក្រុមណាដែលអាចស្រែកបានលឺជាងគេក្រុមនោះជាអ្នកឈ្នះ។

៤. ឲ្យក្រុមដែលឈ្នះរើសកាដូមុន ហើយអ្នកចាញ់រើសតាមក្រោយ។ ក្រុមទាំងពីរត្រូវបើកកកាដូដំណាលគ្នា។ ក្រុមមួយអាចទទួលបានស្ករគ្រាប់ហើយក្រុមមួយទៀតអាចមិនទទួលបានអ្វីទាំងអស់។

៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ប្រសិនបើយើងធ្វើការសម្រេចបានត្រឹមត្រូវ យើងនឹងទទួលបានស្ករគ្រាប់ តែប្រសិនបើយើងធ្វើការសម្រេចចិត្តមិនបានត្រឹមត្រូវទេនោះ យើងនឹងមិនទទួលបានអ្វីនោះទេ។ ព្រះតែងតែផ្ដល់នូវជម្រើសសម្រាប់យើង។

## ៨. ខគម្ពីរចងចាំ

**យ៉ូប ៣៤៖៤** *" សូមឲ្យយើងរាល់គ្នារើសយកសេចក្ដីណាដែលត្រឹមត្រូវសំរាប់ពួកយើង ហើយឲ្យយើងបានស្គាល់សេចក្ដីដែលល្អនៅក្នុងចំណោមយើង។"*

## ៩. ហត្ថកម្ម «ព្រះប្រទានជំរើសដល់យើង- ជ្រើសរើសយកព្រះ!»




១. សូមបោះពុម្ពក្រដាសហត្ថកម្មខាងក្រោមឲ្យទៅកុមារគ្រប់ៗគ្នា

២. សូមពន្យល់កុមារថា យើងទាំងអស់គ្នាត្រូវបានកាត់ចេញពីព្រះដោយសារអំពើបាប។ ប៉ុន្តែដោយសារ ព្រះបានមកសង្គ្រោះយើង ប្រសិនបើយើងជ្រើសរើសព្រះ នោះយើងអាចទៅរស់នៅឯនគរឋានសួគ៌ជា មួយព្រះបាន។

៣. ឲ្យកុមារគូសរូបរបស់ពួកគេនៅក្នុងរង្វង់ចតុកោណកែង ហើយតុបតែងវា។

៤. ឲ្យកុមារសរសេរនៅក្នុងប្រអប់វែងខាងក្រោមថា "ព្រះបានផ្ដល់ជម្រើសឲ្យខ្ញុំ! ខ្ញុំជ្រើសរើសព្រះអង្គ!"

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**
ប្រាជ្ញាដែលបានមកពីទំនាក់ទំនងជាមួយនឹងព្រះយេស៊ូវគឺ គាំទ្រនូវគោលបំណងរបស់ព្រះ។ ប្រាជ្ញាពិតប្រាកដនឹងនាំរាស្ត្ររបស់ព្រះមករកទ្រង់ និងមករកព្រះពររបស់ទ្រង់ជានិច្ច។ សូមអាន **១ពង្សាវតារក្សត្រ ១១៖៣៤-៣៨** តើអ្វីទៅជាទីបញ្ចប់របស់អ៊ីស្រាអែល បើដាវីឌមិនបានគោរពតាមបទបញ្ញានិងច្បាប់របស់ព្រះនោះ? តើព្រះបានសន្យាអ្វីដល់យេរ៉ូបោម បើគាត់ជ្រើសរើសធ្វើតាមព្រះក្នុងការគ្រប់គ្រងរបស់គាត់? ព្រះប្រទានឲ្យយើងនូវការទុកចិត្ត និងព្រះពរស្រដៀងគ្នានេះសម្រាប់មនុស្សជំនាន់ក្រោយ។ តើអ្នកគោរពតាមបទបញ្ញត្តិ និងច្បាប់របស់ព្រះយ៉ាងណា ហើយតើការសម្រេចចិត្តទាំងនេះអាចមានឥទ្ធិពលអ្វីដល់មនុស្សជំនាន់ក្រោយ?

# ព្រះជាម្ចាស់ទ្រង់ផ្តល់ជម្រើសឱ្យយើង-ជ្រើសរើសយកព្រះ

